**Chromebook Webpage Content**

## ហេតុអ្វីបានជាកិច្ចខិតខំប្រឹងប្រែងនេះមានសារៈសំខាន់សម្រាប់សិស្សានុសិស្សនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា?

នៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា គ្រួសារជាច្រើនមានលទ្ធភាពប្រើប្រាស់ កុំព្យូទ័រនៅផ្ទះ និង មានសេវាកម្មអ៊ីនធឺណិត ដើម្បីជួយពង្រីកការសិក្សារបស់កូនៗពួកគាត់ លើសពីនៅក្នុងថ្នាក់រៀន ក្នុងពេលជាមួយគ្នានេះដែរ មានគ្រួសារជាច្រើននៅតែគ្មានលទ្ធភាព។ ការស្ទង់មតិរបស់ក្រសួងឆ្នាំ ២០១៩ បានរកឃើញថា៖

- ៨៥% នៃសិស្សថ្នាក់ទី ៣-៥ មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតពីកុំព្យូទ័រនៅផ្ទះ
- ៩៦% នៃសិស្សថ្នាក់ទី ៦-៨ មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតពីកុំព្យូទ័រនៅផ្ទះ
- ៩៨% នៃសិស្សថ្នាក់ទី ៩-១២ មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតពីកុំព្យូទ័រនៅផ្ទះ

## ចុះការប្រើអ៊ីនធឺណិត?

បន្ថែមលើការឱ្យខ្ចី កុំព្យូទ័រក្រុមប៊ុក ក្រសួងនៅតែបន្តធ្វើការជាមួយសាលាក្រុងដើម្បីបង្កើតបញ្ជីជម្រើសអ៊ីនធឺណិតដែលមានតម្លៃថោក ឬ អាចចូលប្រើ វ៉ាយហ្វាយចល័ត ដោយឥតគិតថ្លៃ នៅទូទាំងទីក្រុង។ បញ្ជីឈ្មោះនេះនឹងមាននៅក្នុងទំព័រវ៉ិបសៃនេះ និង វ៉ិបសៃរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា ក្នុងពេលឆាប់ៗនេះ។

សម្រាប់ក្រុមគ្រួសារដែលរស់នៅតាមតំបន់នានានៃទីក្រុង ដែលមានប្រព័ន្ធ វ៉ាយហ្វាយអ៊ិចហ្វីនីធី ក្រុមហ៊ុនខមខាស្ត កំពុងធ្វើឱ្យ វ៉ាយហ្វាយអ៊ិចហ្វីនីធី ប្រើបានដោយឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នា - រួមទាំងអ្នកដែលមិនមែនជាអតិថិជនរបស់ អ៊ីនធឺណិត អ៊ិចហ្វីនីធី។ ដើម្បីជ្រាបពីផែនទីនៃចំណុច វ៉ាយហ្វាយអ៊ិចហ្វីនីធី សូមមើលក្នុងវ៉ិបសៃ www.xfinity.com/wifi។

## សេចក្តីណែនាំអំពីសុវត្ថិភាព

បុគ្គលិកក្រសួង និង បុគ្គលិកសាលាក្រុង ទាំងអស់ដែលចូលរួមក្នុងការចែកចាយ កុំព្យូទ័រក្រុមប៊ុក នឹងធ្វើតាមសេចក្តីណែនាំអំពីសុវត្ថិភាពយ៉ាងតឹងរឹង ដែលគេបានបង្កើតឡើងដើម្បីធានានូវ សុខភាព និង សុខុមាលភាពរបស់ បុគ្គលិក សិស្សានុសិស្ស និង ក្រុមគ្រួសារ របស់យើង។

## សេចក្តីណែនាំអំពីសុវត្ថិភាពទាំងនេះរួមមាន៖

- ពាក់ស្រោមដៃ និង រក្សាគម្លាតប្រាំមួយ (៦) ហ្វីត ពីមនុស្សគ្រប់គ្នានៅពេលកំពុង រៀបចំ និង ចែកចាយ កុំព្យូទ័រក្រុមប៊ុក
- ជូតសម្អាតគ្រប់កន្លែង មុន និង ក្រោយ ពេលគេប៉ះពាល់៖ តុ ប៊ិច សម្ភារៈ ដៃទ្វារ ។ល។

## ឯកសារជំនួយក្នុងការសិក្សាតាមកុំព្យូទ័រ

នឹងមានក្នុងពេលឆាប់ៗនេះ!